medicare

# ចាប់ផ្តើមការសន្ទនាអំពីវេជ្ជបញ្ជារយៈពេល 60 ថ្ងៃជាមួយវេជ្ជបណ្ឌិតរបស់អ្នក



## គម្រោងការជំនួយផ្នែកឱសថ (PBS) និងវេជ្ជបញ្ជារយៈពេល 60 ថ្ងៃ

គម្រោងការជំនួយផ្នែកឱសថ (PBS) គឺជាកម្មវិធីរបស់រដ្ឋាភិបាលអូស្ត្រាលីដែលឧបត្ថម្ភធនលើឱសថមានវេជ្ជបញ្ជាជាង 900 មុខ ដែលជួយធ្វើឱ្យឱសថត្រូវការជាប្រចាំកាន់តែមានតម្លៃសមរម្យ។ ការនេះធ្វើឱ្យមានភាពខុសគ្នាយ៉ាងច្រើនក្នុងការកាត់បន្ថយការចំណាយលើការថែទាំសុខភាពរបស់អ្នក។






## តើវេជ្ជបញ្ជារយៈពេល 60 ថ្ងៃជាអ្វី?

ឱសថ PBS ស្ទើរតែ 300 មុខ ឥឡូវនេះអាចរកបានសម្រាប់វេជ្ជបញ្ជារយៈពេល 60 ថ្ងៃ។ ប្រសិនបើអ្នកមានស្ថានភាពសុខភាពដែលកំពុងបន្តមានស្ថេរភាព អ្នកអាចទទួលបានការផ្គត់ផ្គង់ឱសថរយៈពេល 60 ថ្ងៃ របស់អ្នកពីវេជ្ជបញ្ជាតែមួយ។ អត្ថប្រយោជន៍នានារួមមាន៖

- ការធ្វើដំណើរកាន់តែតិចជាងមុនទៅឱសថស្ថាន។
- សន្សំសំចៃពេលវេលា និងថវិកា។

**ការណែនាំនេះគឺដើម្បីជួយផ្តល់ឱ្យអ្នកនូវគន្លឹះជាក់ស្តែង និងការចាប់ផ្តើមការសន្ទនា ដូច្នេះអ្នកអាចនិយាយជាមួយវេជ្ជបណ្ឌិតរបស់អ្នកដោយមានទំនុកចិត្តអំពីវេជ្ជបញ្ជារយៈពេល 60 ថ្ងៃ។ ចូរពិនិត្យមើលវាត្រួសៗជាមួយគ្នា។**

# ចាប់ផ្តើមការសន្ទនាជាមួយវេជ្ជបណ្ឌិតរបស់អ្នក

ការនិយាយអំពីវេជ្ជបញ្ជាអាចនឹងមានអារម្មណ៍គួរឱ្យខ្លាច ប៉ុន្តែវាមិនចាំបាច់ត្រូវតែដូច្នោះទេ។ វេជ្ជបណ្ឌិតរបស់អ្នកនៅទីនោះដើម្បីជួយអ្នក។ ដោយការសួរនាំសំណួរត្រឹមត្រូវ និងស្វែងរកជម្រើសនានាដូចជាវេជ្ជបញ្ជារយៈពេល 60 ថ្ងៃ អ្នកអាចគ្រប់គ្រងការថែទាំសុខភាពរបស់អ្នក និងធ្វើការជ្រើសរើសបន្ទាប់ពីជ្រាបព័ត៌មានសព្វគ្រប់ ។

ចាប់ផ្តើមការសន្ទនានៅថ្ងៃនេះ ដើម្បីរីករាយជាមួយអត្ថប្រយោជន៍នៃឱសថដែលកាន់តែមានតម្លៃសមរម្យ និងអាចចូលប្រើប្រាស់បាន។

នេះគឺជាគន្លឹះមួយចំនួនដើម្បីជួយអ្នកបើកការពិភាក្សានេះក្នុងអំឡុងពេលណាត់ជួបទៀងទាត់បន្ទាប់របស់អ្នក៖

- **សួរវេជ្ជបណ្ឌិតរបស់អ្នកអំពីវេជ្ជបញ្ជារយៈពេល 60 ថ្ងៃ** ហើយពិភាក្សាអំពីរបៀបដែលវាអាចដំណើរការសម្រាប់អ្នក។
- **រៀបចំសំណួររបស់អ្នក**ជាមុន។ ពិចារណាការសួរអំពីសិទ្ធិទទួល ជម្រើសឱសថទូទៅ ឬរបៀបដែលសំណាញ់សុវត្ថិភាព PBS អនុវត្តចំពោះអ្នក។
- **យកបញ្ជីឱសថបច្ចុប្បន្នរបស់អ្នក** ដើម្បីជួយវេជ្ជបណ្ឌិត ឬឱសថការីរបស់អ្នកពិនិត្យមើលផែនការព្យាបាលរបស់អ្នកប្រកបដោយប្រសិទ្ធភាព។

តើយើងអាចនិយាយអំពីមធ្យោបាយនានាដែលធ្វើឱ្យឱសថរបស់ខ្ញុំកាន់តែមានតម្លៃសមរម្យបានទេ?

តើឱសថដែលខ្ញុំត្រូវការមានសម្រាប់វេជ្ជបញ្ជារយៈពេល 60 ថ្ងៃទេ ហើយតើខ្ញុំមានសិទ្ធិទទួលដែរឬទេ?



# ប្រធានបទសំខាន់ៗដែលត្រូវពិភាក្សា

តើឱសថនេះដែលអ្នកកំពុងចេញវេជ្ជបញ្ជា មានសម្រាប់វេជ្ជបញ្ជារយៈពេល 60 ថ្ងៃទេ?

ខ្ញុំបានទទួលវេជ្ជបញ្ជារយៈពេល 60 ថ្ងៃសម្រាប់ឱសថនេះ។ តើខ្ញុំអាចបន្តទទួលបានវេជ្ជបញ្ជារយៈពេល 60 ថ្ងៃទេ?

## 1. វេជ្ជបញ្ជារយៈពេល 60 ថ្ងៃ

ឱសថជាច្រើនអាចរកបានសម្រាប់វេជ្ជបញ្ជារយៈពេល 60 ថ្ងៃ។ សូមសួរវេជ្ជបណ្ឌិតរបស់អ្នកថាតើឱសថរបស់អ្នកមានចុះក្នុងបញ្ជីដែរឬអត់។

**អត្ថប្រយោជន៍នៃវេជ្ជបញ្ជារយៈពេល 60 ថ្ងៃ៖**

- ការធ្វើដំណើរកាន់តែតិចទៅឱសថស្ថាន។
- កាត់បន្ថយការចំណាយទៅតាមពេលវេលា។

**គន្លឹះ**ប្រសិនបើអ្នកបានទទួលវេជ្ជបញ្ជារយៈពេល 60 ថ្ងៃ សូមរម្លឹកវេជ្ជបណ្ឌិតរបស់អ្នកតាមបែបគួរសម ដើម្បីបន្តវេជ្ជបញ្ជាទាំងនោះ។

## 2. គម្រោងការជំនួយផ្នែកឱសថ (PBS)

PBS ជួយកាត់បន្ថយថ្លៃឱសថ។ សូមសួរវេជ្ជបណ្ឌិតរបស់អ្នកថាតើមានជម្រើសដែលមានតម្លៃថោកជាងនេះដែរឬទេ ដូចជាឱសថទូទៅ។



តើមានកំណែទូទៅនៃឱសថនេះដែលចុះក្នុងបញ្ជី PBS ដែរឬទេ?

# ពិភាក្សាជាមួយឱសថការីរបស់អ្នក អំពីមធ្យោបាយផ្សេងទៀតដើម្បី សន្សំសំចៃលើឱសថរបស់អ្នក

## 3. សំណាញ់សុវត្ថិភាព PBS

នៅពេលដែលអ្នក ឬគ្រួសាររបស់អ្នកចំណាយ $1,694.00 លើ ឱសថ PBS ក្នុងឆ្នាំប្រតិទិនមួយ អ្នកប្រហែលជាមានសិទ្ធិទទួល បានសំណាញ់សុវត្ថិភាព PBS ដែលកាត់បន្ថយការចំណាយ បន្ថែមទៀត។ សម្រាប់អ្នកកាន់ប័ណ្ណសម្បទាន កម្រិតនោះគឺ $277.20 សម្រាប់ឆ្នាំ 2025។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ servicesaustralia.gov.au /pbs-safety-net-thresholds

តើខ្ញុំខិតជិតដល់សំណាញ់ សុវត្ថិភាព PBS នៅឆ្នាំនេះ ប៉ុណ្ណាដែរ?

តើខ្ញុំត្រូវដាក់ពាក្យសុំប័ណ្ណ សំណាញ់សុវត្ថិភាព PBS ដូចម្តេចដែរ?

ខ្ញុំមានប័ណ្ណសម្បទាន ហើយ បានទទួលឱសថក្នុងតម្លៃថោក ជាងរួចទៅហើយ។ តើវេជ្ជបញ្ជា រយៈពេល 60 ថ្ងៃនឹងនៅតែជួយ ខ្ញុំសន្សំសំចៃប្រាក់ដែរឬទេ?

តើមានកំណែទូទៅនៃឱសថនេះទេ?



## 4. ឱសថទូទៅ

ឱសថទូទៅមានប្រសិទ្ធភាពដូចឱសថ នានាដែលមានឈ្មោះម៉ាកដែរ ប៉ុន្តែ មានតម្លៃថោកជាងច្រើនណាស់។

## ការពុះពារលើឧបសគ្គការសន្ទនា

តើមិនប្រាកដថាត្រូវចាប់ផ្តើមដោយ របៀបណាឬ? នេះគឺជាគំនិតមួយចំនួន៖

តើមានមធ្យាបាយនានា ដើម្បីកាត់បន្ថយថ្លៃឱសថ របស់ខ្ញុំទេ?



ខ្ញុំបានឮអំពីវេជ្ជបញ្ជារយៈពេល 60 ថ្ងៃ ហើយចង់ដឹងថាតើខ្ញុំមាន សិទ្ធិទទួលដែរឬទេ។

តើអ្នកអាចជួយខ្ញុំឱ្យយល់ថាតើ សំណាញ់សុវត្ថិភាព PBS ជាអ្វី និង របៀបដែលវាដំណើរការសម្រាប់ខ្ញុំ បានទេ?

តើអ្នកគិតថាវេជ្ជបញ្ជា រយៈពេល 60 ថ្ងៃនឹង ត្រឹមត្រូវសម្រាប់ខ្ញុំទេ?



## ជំហានបន្ទាប់

1. **ធ្វើការណាត់ជួបជាមួយវេជ្ជបណ្ឌិតរបស់អ្នក។** ពិនិត្យមើលឱសថរបស់អ្នក និងពិភាក្សាអំពីវេជ្ជបញ្ជា រយៈពេល 60 ថ្ងៃ។
2. **ពិនិត្យមើលសិទ្ធិទទួលរបស់អ្នក**។ ដើម្បីស្វែងយល់ បន្ថែម សូមចូលទៅកាន់គេហទំព័រ health.gov.au/cheapermedicines។
3. **និយាយជាមួយឱសថការីរបស់អ្នក។** ពួកគេគឺជាធនធាន ដ៏ល្អសម្រាប់ការគ្រប់គ្រងឱសថ។ ពួកគេក៏អាចជួយអ្នកឱ្យ យល់ពីការចំណាយរបស់អ្នក និងបណ្តាញសុវត្ថិភាព PBS ដែរ។

# ការចូលប្រើប្រាស់ធនធានពហុភាសា

តើអ្នកដឹងថាធនធាននានាអំពី PBS និងវេជ្ជបញ្ជារយៈពេល 60 ថ្ងៃមានជាច្រើនភាសាដែរឬទេ? វេជ្ជបណ្ឌិត ឬឱសថការីរបស់អ្នកអាចផ្តល់សម្ភារៈទាំងនេះ ដើម្បីជួយអ្នកឱ្យយល់កាន់តែច្បាស់អំពីជម្រើសនានារបស់អ្នក។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ health.gov.au/cheapermedicines/translated។











**សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ ៖**

health.gov.au/cheapermedicines

**សម្រាប់ធនធានជាភាសាខ្មែរ សូមចូលទៅកាន់គេហទំព័រ ៖**

health.gov.au/cheapermedicines/translated